## ឧបសម្ព័ន្ធទី ៥: ការការពារចំការឈើ

### ១. ការការពារទប់ទល់នឹងភ្លើង

ការបង្កើតប្រព័ន្ធការពារភ្លើងព្រៃគឺជាការចាំបាច់ហើយការងារនេះត្រូវដាក់បញ្ចូលទៅក្នុងផែនការការងារចាប់ពីដើមដំបូង។ ក្នុងការបង្កើតប្រព័ន្ធការពារភ្លើងព្រៃ ចំការឈើត្រូវបែងចែកជាប្លុក។ ទំហំប្លុកអាស្រ័យនឹងទំហំចំការឈើ ហើយមិនត្រូវមានទំហំតូចពេកនោះទេ ព្រោះវានឹងទាមទារឱ្យមានការកសាងផ្លូវច្រើន ប៉ុន្តែមិនត្រូវមានទំហំធំពេកដែរព្រោះមិនអាចការពារភ្លើងព្រៃបានដោយប្រសិទ្ធភាព។ ទំហំប្លុកដែលសមស្រប ហើយដែលកំណត់ឱ្យប្រើដោយរដ្ឋបាលព្រៃឈើគឺ ២៥ ហត ឬតូចជាងនេះ។ ប្លុកទាំងនេះត្រូវបានញែក ចេញពីគ្នាដោយសារផ្លូវភ្លើងដែលអាចជាផ្លូវលំ ផ្ទៃដីព្រៃដែលបានកាប់សំអាត អូរ និង បន្ទាត់រុក្ខជាតិបៃតង។




### ១.១ ទទឹងផ្លូវភ្លើង

ជាការលំបាកក្នុងការនិយាយថាតើផ្លូវភ្លើងគួរមានទំហំប៉ុណ្ណា ហើយជាយោបល់គួរថិតក្នុងក៏រិតពី ៦-៣០ ម ឬលើស។ ទោះបីជាផ្លូវភ្លើងដែលមានទំហំធំក៏ដោយ ក៏មិនអាចធានាការឆ្លងកាត់នៃភ្លើងព្រៃបានដែរហើយ លើសពីនេះ ផ្លូវធំពិបាកក្នុងការថែរក្សាទៀតផង។ ដូច្នេះជាការប្រសើរគេត្រូវប្រើប្រាស់នូវផ្លូវភ្លើងដែលមានស្រាប់ដោយធម្មជាតិឬបង្កើតផ្លូវភ្លើងដោយកំរាលបៃតង( ទំព័របន្ទាប់) និងថែមទាំងអាចផ្តល់ផលទៀតផង។ ផ្លូវភ្លើងដែលកាត់ទទឹងជំរាលត្រូវមានទទឹងធំជាងផ្លូវភ្លើងដែលរត់តាមបណ្តោយជំរាល ដោយសារភ្លើងព្រៃអាចឆេះឡើងទៅរកកំពូលភ្នំដោយស្រួល។

### ១.២ ប្រភេទផ្លូវភ្លើង

*ផ្លូវភ្លើងដោយធម្មជាតិ:*រួមមានផ្លូវទឹកដែលមានអូរ ជ្រោះ និង ផ្ទាំងថ្មដាជាដើម។ ផ្លូវភ្លើងដែលមានស្រាប់ផ្សេងទៀតដូចជាផ្លូវថ្នល់ ផ្លូវលំ និងវាលស្រែ ។ល។

ត្រូវប្រើប្រាស់ផ្លូវភ្លើងធម្មជាតិ និងផ្លូវភ្លើងដែលបង្កើតដោយមនុស្សនិងមានស្រាប់នៅនឹងទីកន្លែងដោយត្រូវពង្រីកទទឹងបន្ថែម ។ ផ្លូវភ្លើងដោយកំរាលបៃតងរួមមានព្រៃឈើ និងតំបន់កសិកម្ម ជាពិសេសព្រៃស្រោងសើម ។

ត្រូវយកចេញនូវកំទេចកំទីមែកឈើ និង វត្ថុដែលអាចឆេះបានចេញពីជាយព្រៃ និង ព្រៃគុម្ពោតដែលមានស្រាប់ ដើម្បីធ្វើឱ្យតំបន់ទាំងនោះក្លាយជាផ្លូវភ្លើងដោយមានប្រសិទ្ធិភាព ។

*ផ្លូវភ្លើងរស់ ឬផ្លូវភ្លើងដែលមានកំរាលបៃតង:* ដាំដើមឈើក្នុងគំលាតញឹក (ឧទាហរណ៍ ១ម x ១ម) ដើម្បីឱ្យគំរបព្រៃឆាប់ប៉ះគ្នានិងគ្របស្មៅបានឆាប់រហ័ស ។ប្រភេទឈើដែលអាចប្រើជាផ្លូវភ្លើងរស់ រួមមានកន្ទុំថេត ផ្គុង ព្រីង ពពូល ។ល ។

*ផ្លូវភ្លើងចំរុះ:* គេដាំដំណាំកសិកម្ម និងដើមឈើ នៅក្នុងផ្លូវភ្លើង ។




ប្រភព: *Kathleen et al 199:* **ផ្លូវភ្លើងដែលមានកំរាលបៃតង**

ផ្លូវភ្លើងដែលស្អាត គឺជាផ្លូវភ្លើងដែលបានសំអាតយករុក្ខជាតិចេញអស់ដោយការកាប់ ឬគាស់ចេញ។ វិធីសាស្រ្តនេះ មិនគួរអនុវត្តទេសំរាប់ផ្លូវភ្លើងអចិន្ត្រៃយ៍ ដោយសារទាមទារឱ្យមានការចំណាយកំលាំងពលកម្ម ច្រើន និង មិនសូវមានប្រសិទ្ធិភាព ដូចជាគេត្រូវកាប់ឬគាស់យកស្បូវចេញជារៀងរាល់ឆ្នាំមុនពេលដែលរុក្ខជាតិនេះស្ងួតងាយស្រួលឱ្យភ្លើងឆេះ ។

## ២. ការជំរះស្មៅ*

ការជំរះស្មៅនៅក្នុងចំការដាំឈើរួមមានការងារសំខាន់ៗចំនួនពីរគឺៈការកាត់ស្មៅដែលដុះជុំវិញកូនឈើនិងការជីកគាស់ស្មៅទាំងឫស ។ ការជំរះស្មៅគួរអនុវត្តន៍ក្នុងរង្វង់ ១ម ជុំវិញកូនឈើ ។ សំអាតឬដកចេញតែស្មៅណាដែល

---

*(*): ចំណុចនេះត្រូវបានដកស្រង់ និង សំរួលពី Forestry / Fuelwood Research and Development Project.1994.*

រំខានដល់ការដុះលូតលាស់នៃកូនឈើ ហើយទុកពពួករុក្ខជាតិទាំងឡាយណាដែលមិនរំខានដល់កូនឈើនិងអាចជួយសំរួលដល់មីក្រូអាកាសធាតុ។ ការងារសំអាតស្មៅអាចអនុវត្តបានតាមរបៀបដូចខាងក្រោម:

- o វិធីមេកានិក (ការដកស្មៅដោយដៃ ឬដោយប្រើឧបករណ៍សាមញ្ញ): នៅតំបន់ដែលមានកំលាំងពលកម្មថោក ហើយសំបូរ នោះការងារសំអាតស្មៅអាចធ្វើឡើងដោយដៃ។ តាមវិធីនេះគេកាប់សំអាតស្មៅដោយកាំបិត ឬកាំបិតដងវែងនៅត្រឹមផ្ទៃដី។ កសិករភាគច្រើននិយមគាស់ស្មៅចោលទាំងឫសដោយប្រើចបកាប់។ គេអាចប្រើវិធីនេះដើម្បី សំអាតស្មៅនៅទូទាំងចំការ ឬសំអាតជាជួរៗ។
- o វិធីជីវសាស្ត្រ: តាមវិធីនេះគេប្រើប្រាស់រុក្ខជាតិគ្របដីដែលសមស្របដោយប្រើប្រាស់ដង់ស៊ីតេកូនឈើឱ្យបានសមរម្យ ដោយការត្រួតពិនិត្យការលែងសត្វពាហនៈ ហើយគួរសាកល្បងប្រើប្រាស់សត្វល្អិតដែលស៊ីស្មៅជាអាហារ។
- o ចំនួនដងនៃការដកស្មៅ: គួរដកស្មៅមុនពេលដែលវាទុំនិងជំរុះគ្រាប់ គឺនៅក្នុងកំឡុងពេលពី ៦-៨ ខែ បន្ទាប់ពីកូនឈើបានដាំ។ នៅឆ្នាំទីមួយចំការកូនឈើត្រូវសំអាតស្មៅរៀងរាល់ ៦ ខែម្តង ហើយបន្តអនុវត្តរបៀបនេះរហូតដល់កូនឈើមានកន្សោមស្លឹកប៉ះគ្នាដែលនៅពេលនេះចំការកូនឈើមានលទ្ធភាពរារាំងការដុះលូតលាស់នៃស្មៅចង្រៃបាន។

## ៣. ការជ្រួយដី

ការជ្រួយដីជួយបង្កើនការស្រូបសំណើម កាត់បន្ថយកំហាប់ដី បង្កើនលំហនៅក្នុងដី បន្ថយការបាត់បង់ទឹក បង្កើនរចនាសំព័ន្ធដី កាត់បន្ថយការដុះស្មៅ និងកាត់បន្ថយភាពកក្វក់នៃចំការឈើ។ ការជ្រួយដីជុំវិញកូនឈើមានសារសំខាន់ជាពិសេសនៅឆ្នាំទីមួយ។ ការជ្រួយដីជុំវិញកូនឈើអាចធ្វើដោយដៃឬដោយគ្រឿងចក្រនៅជុំវិញគល់កូនឈើក្នុង ចំងាយ ៥០ សម។

## ៤. ការគ្របគល់ឈើដោយកំទេចកំទីសំរាម

ការគ្របគល់ឈើដោយកំទេចកំទីសំរាម កាន់តែមានការនិយមកាន់តែច្រើនឡើងៗក្នុងការការពារស្មៅចង្រៃ។ វិធីនេះជួយការពារមិនឱ្យពន្លឺថ្ងៃចុះទៅដល់ដីដូច្នេះស្មៅមិនអាចដុះកើត។ មានវត្ថុធាតុដើមជាច្រើនដែលអាចប្រើប្រាស់ក្នុងការងារនេះដូចជា: អាចម៍គោ ចំបើង អាចម៍រណា ចំណាំងឈើនិងសំបកឈើ។ សូម្បីតែប្លាស្ទិក និង ដុំថ្ម ក៏អាចប្រើក្នុងការការពាកំដៅថ្ងៃ និងការភាយហួតចំហាយទឹកបានដែរ។

ផលប្រយោជន៍នៃការគ្របគល់ឈើដោយកំទេចកំទីសំរាមគឺ ការពារសំណើមដី ការពារការហូរច្រោះដី រក្សារចនាសំព័ន្ធដីបង្កើនចំនួនពពួកមីក្រុបបង្កើនលក្ខណ:សម្បត្តិនៃរូបសាស្ត្រគីមីនិងកាត់បន្ថយការដុះស្មៅ។ ដូច្នេះ ការគ្របគល់ឈើដោយកំទេចកំទីសំរាមធ្វើឱ្យស្រទាប់លើនៃដីត្រជាក់សើម និងងាយជ្រាបទឹក។

## ៥. ការដាក់ជី

ចំពោះចំការឈើដាំដែលមានទំហំធំៗ ការដាក់ជីហាក់ដូចជាមិនមានការអនុវត្តទេ។ ប្រភេទជីគីមីដែលគេនិយមប្រើក្នុងវិស័យព្រៃឈើគឺ NPK: 12:12:12។ គេអាចដាក់ជីអ៊ុយរ៉េ ក្នុងកំឡុងពេលស្រោចទឹក ឬ មុនពេលភ្លៀងធ្លាក់ ដោយដាក់ក្នុងកំរិត ១០-២០ ក្រាម សំរាប់កូនឈើនិមួយៗ ដោយរោយជុំវិញគល់កូនឈើ។ របៀបដាក់ជីគឺត្រូវដាក់ជារាងរង្វង់ ក្នុងចំងាយប្រមាណ ៣០ សម ពីគល់កូនឈើ។ ការដាក់ជីកៀកនឹងគល់កូនឈើពេកនឹងធ្វើឱ្យកូនឈើខូចខាតឬស្លាប់តែម្តង។ ក្នុងមួយឆ្នាំគេអាចដាក់ជីចំនួនពីរដងនៅក្នុងរដូវភ្លៀង (Siyag, 1998)។

ដោយឡែកជីសរីរាង្គគឺជាប្រភេទជីដែលគេនិយមចូលចិត្ត។ ជីកំប៉ុស្ត ជីលាមកសត្វ និងសំរាមដែលប្រមូលពីលំនៅដ្ឋានអាចប្រើជាជីបានយ៉ាងល្អប្រណីត។ ក្នុងមួយឆ្នាំគេអាចដាក់ជីសរីរាង្គចំនួនមួយដង។

ការដាក់ជីគីមី និង ជីសរីរាង្គនឹងមិនចាំបាច់ទៀតទេ បន្ទាប់ពីកូនឈើដាំអាយុបានបីឆ្នាំ។

## ៦. ការធ្វើឱ្យរហាល*

ការធ្វើឱ្យរហាលគឺជាការកាប់ដកចេញនូវដើមឈើមួយដើមៗ ដែលគេច្រើនតែអនុវត្តនៅក្នុងដំណុះឈើដែលមិនទាន់ពេញវ័យ ដើម្បីបង្កើនល្បឿនដុះលូតលាស់នៃដើមឈើដែលបន្សល់ទុក។ ការធ្វើឱ្យរហាលមានភាពចាំបាច់សំរាប់ចំការឈើដាំដើម្បីផលិតជាឈើអារ ក្តារបន្ទះ និង សរសរធំៗ។ ប្រសិនបើដាំឈើដើម្បីផលិតឈើឱ្យបានច្រើនក្នុងមួយហិកតា តែត្រូវការដើមឈើតូចៗដូចជាសំរាប់ធ្វើម្សៅក្រដាស នោះគេមិនចាំបាច់ធ្វើឱ្យរហាលទេ។ ការធ្វើឱ្យរហាលគឺជាការកាប់ដកចេញ ដោយជ្រើសរើសនូវដើមឈើដែលមានគុណភាពអន់ ហើយជាលទ្ធផលដើមឈើដែលបន្សល់ទុកនឹងដុះលូតលាស់លឿន ដោយសារការប្រកួតប្រជែងខាងពន្លឺ សំណើមនិងជីជាតិដីមានតិចតួច។

ការធ្វើឱ្យរហាលជួយបង្កើនគុណភាពចំការឈើដាំដោយសារ(១): គេបានកាប់ដកហូតចេញអស់នូវដើមឈើដែលមានជំងឺ ពុក និងវៀចកោងចេញអស់។ (២): សន្សំសំចៃប្រភេទឈើពាណិជកម្ម ធានាការដុះលូតលាស់នៃដើមឈើដែលបន្សល់ទុក និង បង្កើនគុណភាពនៃដើមឈើទាំងនោះផងដែរ។ វិធីសាស្ត្រធ្វើឱ្យរហាលដែលគេនិយមអនុវត្តមានដូចខាងក្រោម:

***ការធ្វើឱ្យរហាលតាមជួរ:*** វិធីនេះអនុវត្តនៅតំបន់ដែលមិនសូវសំបូរកំលាំងពលកម្ម ឬនៅពេលដែលមានការប្រើប្រាស់គ្រឿងចក្រដើម្បីកាប់ដកហូតឈើ។ ការធ្វើឱ្យរហាលលើកទីមួយគេកាប់ដកហូតនូវរាល់ជួរទីបីនៃ ដើមឈើ ហើយមិនប៉ះពាល់ដើមឈើពីរជួរទៀតទេ។

***ការធ្វើឱ្យរហាលដោយជ្រើសរើស:*** វិធីនេះអនុវត្តដោយដកហូតយកចេញនូវដើមឈើដែលមានគុណភាពមិនល្អដូចជាមានជំងឺឬដើមឈើងាប់និងដើមឈើដែលមានគុណភាពសេនេទិកមិនល្អដូចជាដើមឈើវៀចកោងជាដើម។

---

*(*): ចំណុចនេះត្រូវបានដកស្រង់ និង សំរួលពី Forestry / Fuelwood Research and Development Project.1994.*

***ការធ្វើឱ្យរហាលដោយគ្រឿងចក្រ:*** វិធីនេះអនុវត្តដោយប្រើត្រាក់ទ័រឈូសដី ឬត្រាក់ទ័រដែលមានភ្ជាប់នង្គ័លភ្ជួរដីដោយត្រូវភ្ជួរដកហូតយកចេញនូវជួរដើមឈើជាចន្លោះៗ។ គេប្រើវិធីនេះនៅក្នុងចំការឈើដែលមាន លក្ខណៈឯកសណ្ឋាន។

***ការធ្វើឱ្យរហាលដោយប្រើកំណាត់ដំបង:***ជួនកាលគេអនុវត្តនៅក្នុងដំណុះព្រៃធម្មជាតិ ដោយត្រដាងកំណាត់ដំបងមានប្រវែងកំណត់មួយតាមការចង់បានរួចដើរកាត់ព្រៃនៅពេលដែលកំណាត់ដំបងនោះប៉ះដើមឈើពីរ ដើមដំណាលគ្នានោះគេត្រូវកាប់ដកហូតនូវដើមឈើដែលមានគុណភាពអន់។ ជាលទ្ធផលគំលាតមធ្យមដែល នៅសល់មានប្រមាណ ១.៥ ដង នៃប្រវែងកំណាត់ឈើ។ ដើម្បីធ្វើឱ្យរហាលដំណុះឈើមួយដោយបន្សល់ទុកគំលាតប្រមាណ ៣ ម នោះគេត្រូវប្រើកំណាត់ឈើដែលមានប្រវែង ២ម។